កំ

# មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ១៦-៧-២០០០ | -ព្រះរាជក្រឹត្យ នស/រកត/០៧០០/១២៥ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ក្រសួងមហាផ្ទៃ | ១២០៨ |
| ១៦-៧-២០០០ | -ព្រះរាជក្រឹត្យ នស/រកត/០៧០០/១២៧ តែងតាំង និងតំកល់ទុក ឯកឧត្តម ឆា ផលា ជាអគ្គលេខាធិការ នៃអាជ្ញាធរជាតិ ប្រយុទ្ធនឹងជម្ងឺអេដស៍ | ១២១៣ |
| ៩-៧-២០០០ | -ព្រះរាជក្រឹត្យ នស/រកត/០៧០០/១២៧ តែងតាំងឯកឧត្តម គឹម សួខុន ជាទីប្រឹក្សាផ្ទាល់ ឯកឧត្តម ញឹក ប៊ុនឆៃ អនុប្រធានទី២ នៃព្រឹទ្ធសភា | ១២១៤ |
| ២០០០ | -ព្រះរាជក្រឹត្យ នស/រកត/០៧០០/១២៨ តែងតាំងឯកឧត្តម ឈួន ចន្ទឆាយា ជាទីប្រឹក្សាផ្ទាល់ឯកឧត្តម ញឹក ប៊ុនឆៃ អនុប្រធានទី២ នៃព្រឹទ្ធសភា | ១២១៥ |
| ២២-៧-២០០០ | -ព្រះរាជក្រឹត្យ នស/រកត/០៧០០/១២៩ ព្រះរាជទាននូវគ្រឿង ឥស្សរិយយសថ្នាក់អស្សឫទ្ធិ ជូនមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ | ១២១៦ |
| ២២-៧-២០០០ | -ព្រះរាជក្រឹត្យ នស/រកត/០៧០០/១៣០ ផ្តល់សញ្ជាតិខ្មែរតាមសញ្ញាតូបនីយកម្ម ជូនលោក ហ្គុតប៊ី ហ្វេរីឌុន ( GHOTBI FERYDOON ) | ១២១៧ |
| ២២-៧-២០០០ | -ព្រះរាជក្រឹត្យ នស/រកត/០៧០០/១៣១ ផ្តល់សញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍ ជូនលោក JANICK RUBELI | ១២១៨ |
| ២២-៧-២០០០ | -ព្រះរាជក្រឹត្យ នស/រកត/០៧០០/១៣២ ផ្តល់សញ្ជាតិខ្មែរតាមសញ្ញាតូបនីយកម្ម ជូនលោក យ៉ាំ ស៊ុយសាំង ( YUM SUI SANG ) | ១២១៩ |
| ២២-៧-២០០០ | -ព្រះរាជក្រឹត្យ នស/រកត/០៧០០/១៣៣ តែងតាំងមន្ត្រីរាជការជាន់ខ្ពស់ នៃក្រសួងសាធារណការ និង ដឹកជញ្ជូន | ១២២០ |


## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


| | | |
|---|---|---|
| ១៧-៧-២០០០ | -អនុក្រឹត្យលេខ ៥៣ អនក្រ.បក ស្តីពីការបង្កើតវិទ្យាស្ថានគ្រប់គ្រង និង សេដ្ឋកិច្ច | ១២២១ |

១៧-៧-២០០០ -អនុក្រឹត្យលេខ ៥៥ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់រាជបណ្ឌិតសភាកម្ពុជា ១២២៣

២១-៧-២០០០ -អនុក្រឹត្យលេខ ២៦៧ អនក្រ.តត ស្តីពីការតម្លើងឋានន្តរសក្តិនាយទាហាន ១២៣៦

២១-៧-២០០០ -អនុក្រឹត្យលេខ ២៦៨ អនក្រ.តត ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពគណៈកម្មការ POW / MIA កម្ពុជា ១២៣៧

២១-៧-២០០០ -អនុក្រឹត្យលេខ ២៦៩ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១២៣៩


## ២-សេចក្តីសំរេច


១៨-៧-២០០០ -សេចក្តីសំរេចលេខ ៥៨ សសរ ស្តីពីការបង្កើតគណៈកម្មការជំរុញការអនុវត្តន៍កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលជាមួយក្រុមហ៊ុន អារីស្តុន ស្តីពីការអភិវឌ្ឍន៍តំបន់ក្រុងព្រះសីហនុ និងដោះស្រាយបាតុភាពទំនាស់ដីធ្លីនៅតំបន់អូរព្រៃ ១២៤០


# III- ការិយាល័យក្រសួង

## ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

### ប្រកាស


២១-៧-២០០០ -ប្រកាសលេខ ៦៣៥ ឧសករថ.ប្រក ស្តីពីការបង្កើតគណៈកម្មការ កសាងផែនការមេ របស់ក្រសួង ១២៤២


## ២-ទីស្តីការរដ្ឋមន្ត្រី ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

### ប្រកាស


២១-៧-២០០០ -ប្រកាសលេខ ១៥០ បទ.ប្រក ស្តីពីការបង្កើតអនុគណៈកម្មាធិការអន្តរក្រសួងពត៌មានវិទ្យា និងមីក្រូអេឡិចត្រូនិក ១២៤៤

# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ

### ព្រះរាជក្រឹត្យ នស/រកត/០៧០០/១២៥

### ស្តីពី លក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌថ្នាក់ខាងរដ្ឋបាលក្រសួងមហាផ្ទៃ

***

**យើង**

**ព្រះបាទសម្តេចព្រះនរោត្តមសីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

****

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ [illegible]/១២[illegible] [illegible] ១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពី គោលការណ៍រួមនៃការរៀបចំអង្គភាពសាធារណៈរបស់រដ្ឋ
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០០

## គ្រាស់បន្ទាប់

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ ._**

ត្រូវបានបង្កើតក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាលរបស់ក្រសួងមហាផ្ទៃ ដែលត្រូវបានចាត់ថ្នាក់ក្នុងប្រភេទ ឃ ដូចបានចែងក្នុងមាត្រា ៦ នៃព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ ។

**មាត្រា ២ ._**

មន្ត្រីរាជការនៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាលនេះ ត្រូវស្ថិតនៅក្រោមឱវាទក្រសួងមហាផ្ទៃ ។

**មាត្រា ៣ ._**

មន្ត្រីរាជការ នៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល មានឧបនិស្ស័យសំរាប់បំពេញមុខតំណែងក្នុងកិច្ចការប្រតិបត្តិមុខងារសាមញ្ញ នៅក្នុងអង្គភាពរដ្ឋបាលកណ្តាលរបស់ក្រសួងមហាផ្ទៃ និង តាមខេត្ត ក្រុង ។

## ជំពូកទី ២

## ឋានន្តរសក្តិ នៃក្របខ័ណ្ឌ

**មាត្រា ៤ ._**

ក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាលក្រសួងមហាផ្ទៃមាន ៣ ឋានន្តរសក្តិ :

| | | | | |
|---|---|---|---|---|
| -នាយភ្នាក់ងាររដ្ឋបាល | : | មាន | ០៦ | ថ្នាក់ |
| -ភ្នាក់ងាររដ្ឋបាលដើមខ្សែ | : | មាន | ១០ | ថ្នាក់ |
| -ភ្នាក់ងាររដ្ឋបាល | : | មាន | ១៤ | ថ្នាក់ ។ |

## ជំពូកទី ៣

## ការជ្រើសរើស

**មាត្រា ៥ ._**

ការជ្រើសរើសចូលក្នុងក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាលក្រសួងមហាផ្ទៃ ត្រូវធ្វើតាមរបៀបការប្រឡងប្រជែងដែលរៀបចំឡើង ដោយក្រសួងមហាផ្ទៃ ។ ចំនួននៃតំណែងក្នុងការជ្រើសរើស ត្រូវកំណត់ឡើងដោយរាជរដ្ឋាភិបាលតាមសំណើរបស់ក្រសួងមហាផ្ទៃ ។

**ប្រការ ៦ ._**

ការប្រឡងប្រជែងជ្រើសរើស ត្រូវបើកចំហចំពោះបេក្ខជនដែលមានអាយុយ៉ាងច្រើន ២៥ ឆ្នាំ គិតរហូតដល់ថ្ងៃប្រឡង ។ អាយុនេះអាចរំកិលពី ២៥ ឆ្នាំ ឡើងដល់ ៣០ ឆ្នាំ ស្របតាមមាត្រា ១១ នៃសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

## ជំពូកទី ៤
## កម្មសិក្សាសាកល្បង និង ការតាំងស៊ប់

**មាត្រា ៧ ._**

បេក្ខជនដែលត្រូវបានជ្រើសរើស ចាំបាច់ត្រូវឆ្លងកាត់រយៈពេលធ្វើកម្មសិក្សាមួយ ដែលប្រព្រឹត្តទៅស្របតាមមាត្រា ១៦ និងមាត្រាបន្តបន្ទាប់ នៃសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។ ក្រោយពេលធ្វើកម្មសិក្សាសាកល្បង មន្ត្រីទាំងនេះត្រូវបានតាំងស៊ប់ក្នុងឋានន្តរស័ក្តិភ្នាក់ងាររដ្ឋបាល ឬ ក្នុងករណីចាំបាច់អាចត្រូវបានអនុញ្ញាតអោយធ្វើកម្មសិក្សាបន្តបន្ថែម ដែលមានរយៈពេលអតិបរមាត្រឹម ១២ ខែ ។ មន្ត្រីដែលពុំបានទទួលជោគជ័យក្នុងការធ្វើកម្មសិក្សាបន្ថែមនេះ ត្រូវបានលុបឈ្មោះចោល ។ ករណីខាងលើទាំងនេះនេះត្រូវសំរេចដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ហើយត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរ ០៣ ខែ ក្រោយការបញ្ចប់កម្មសិក្សា ។ ការតែងតាំងជាភ្នាក់ងាររដ្ឋបាលកម្មសិក្សា និងការតាំងស៊ប់ក្នុងឋានន្តរស័ក្តិភ្នាក់ងាររដ្ឋបាលនៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ត្រូវធ្វើឡើងដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

## ជំពូកទី ៥
## ការតែងតាំង

**មាត្រា ៨ ._**

ក្រោយពេលត្រូវបានតាំងស៊ប់ក្នុងឋានន្តរស័ក្តិមួយរួចហើយ មន្ត្រីក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាលក្រសួងមហាផ្ទៃទាំងនេះ ត្រូវបានតែងតាំងក្នុងមុខតំណែងទំនេរណាមួយ ដែលស្របជាមួយឋានន្តរស័ក្តិរបស់ខ្លួន ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ តាមបែបបទដូចបានកំណត់ក្នុងមាត្រា ២៩ នៃព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ។

## ជំពូកទី ៦
## ការតម្លើងថ្នាក់ និងការតម្លើងឋានន្តរស័ក្តិ

**មាត្រា ៩ ._**

មន្ត្រីនៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាលក្រសួងមហាផ្ទៃ ត្រូវបានតម្លើងថ្នាក់ទៅតាមលក្ខខ័ណ្ឌដូចបានចែងក្នុងមាត្រា ២០ និងមាត្រាបន្តបន្ទាប់នៃសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

លក្ខណៈសម្បត្តិជាមូលដ្ឋានដែលត្រូវពិនិត្យតម្លើងថ្នាក់មានដូចខាងក្រោម :

-គោរពវិន័យការងារបានត្រឹមត្រូវ

-សំរេចបានល្អនូវភារកិច្ចដែលប្រគល់អោយ

-មានសីលធម៌ល្អ ។

ការឡើងថ្នាក់ នៃអ្នករាជការក្នុងក្របខ័ណ្ឌនេះ ត្រូវគិតក្នុងសមាមាត្រ ៣ភាគ៤ តាមវេនជ្រើសរើស និង ១ភាគ៤ តាមវេនអតីតភាព ។

មាត្រា ១០ ._

គោលការណ៍នៃការតម្លើងឋានន្តរស័ក្តិ ត្រូវតម្លើងទៅក្នុងថ្នាក់ដំបូងនៃឋានន្តរស័ក្តិខ្ពស់លើបន្ទាប់ ឬក្នុងករណីចាំបាច់ ត្រូវតម្លើងទៅក្នុងថ្នាក់ ដែលស្របជាមួយសន្ទស្សន៍ខ្ពស់លើបន្ទាប់ ពីសន្ទស្សន៍ចាស់របស់មន្ត្រីសាមី ។

ការតម្លើងឋានន្តរស័ក្តិ ត្រូវអនុវត្តអោយបានស្របជាមួយចំនួនកំណែងដែលទំនេរ នៅក្នុងឋានន្តរស័ក្តិនោះ ហើយត្រូវធ្វើតាមរបៀបការចុះឈ្មោះក្នុងតារាងតម្លើងឋានន្តរស័ក្តិ ឬ តាមរបៀបការប្រឡងប្រជែង ដោយរក្សាគោលការណ៍គិតជាភាគរយ ៖

-ឋានន្តរស័ក្តិនាយភ្នាក់ងាររដ្ឋបាល = ៥ ភាគរយ

-ឋានន្តរស័ក្តិភ្នាក់ងាររដ្ឋបាលដើមខ្សែ = ២៥ ភាគរយ

-ឋានន្តរស័ក្តិភ្នាក់ងាររដ្ឋបាល = ៧០ ភាគរយ

ការតម្លើងថ្នាក់ និង ការតម្លើងឋានន្តរស័ក្តិ ត្រូវសំរេចដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

មាត្រា ១១ ._

អាចតម្លើងទៅក្នុងឋានន្តរស័ក្តិភ្នាក់ងាររដ្ឋបាលដើមខ្សែ គឺមន្ត្រីទាំងឡាយណា ដែលបានឡើងដល់ថ្នាក់លេខ ១១ នៃឋានន្តរស័ក្តិភ្នាក់ងាររដ្ឋបាល ។

អាចតម្លើងទៅក្នុងឋានន្តរស័ក្តិនាយភ្នាក់ងាររដ្ឋបាល គឺមន្ត្រីទាំងឡាយណា ដែលបានឡើងដល់ថ្នាក់លេខ ៧ នៃឋានន្តរស័ក្តិភ្នាក់ងាររដ្ឋបាលដើមខ្សែ ។

មាត្រា ១២ ._

សន្ទស្សន៍សំរាប់ថ្នាក់ក្នុងឋានន្តរស័ក្តិនីមួយៗ នៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល និងតម្លៃឯកត្តា នៃសន្ទស្សន៍ ព្រមទាំងរបបលាភការផ្សេងៗទៀត ត្រូវកំណត់ដោយព្រះរាជក្រឹត្យដោយឡែក ។

## ជំពូកទី ៧

## បទប្បញ្ញត្តិដោយឡែក

មាត្រា ១៣ ._

មន្ត្រី នៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ក្រសួងមហាផ្ទៃ ត្រូវដាក់អោយចូលនិវត្តន៍ នៅពេលដល់អាយុ ៥៥ ឆ្នាំ ។

ចំពោះការដាក់អោយចូលនិវត្តន៍ ត្រូវសំរេចដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

## ជំពូកទី ៨

## អន្តរប្បញ្ញត្តិ

មាត្រា ១៤ ._

ចំនួនដំបូងនៃក្របខ័ណ្ឌថ្នាក់ងាររដ្ឋបាលក្រសួងមហាផ្ទៃ ត្រូវកសាងចេញពីសមាហរណកម្ម នៃមន្ត្រីរាជការទាំងឡាយ ដែលបច្ចុប្បន្នកំពុងបំពេញមុខងារពិតប្រាកដ របស់ក្របខ័ណ្ឌក្នុងរដ្ឋបាលកណ្តាល របស់ក្រសួងមហាផ្ទៃ និងតាមខេត្ត ក្រុង ។

## ជំពូកទី ៩

## អវសានប្បញ្ញត្តិ

មាត្រា ១៥ ._

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ១៦ ._

នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តព្រះរាជ-ក្រឹត្យនេះ ។

មាត្រា ១៧ ._

ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០០

ព្រះហស្តលេខា

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រ សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

ហត្ថលេខា

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូនសម្តេច

នាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

ហត្ថលេខា

**ស ខេង យូ ហុកគ្រី**

★★★

# ព្រះរាជក្រឹត្យ នស/រកត/០៧០០/១២៦

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

****

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត០១០០/០០៧ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០០ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធ និងជំងឺអេដស៍
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៩/១៥៨ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការតែងតាំងឯកឧត្តម ឆា ផលា ជាអគ្គលេខាធិការ នៃអាជ្ញាធរជាតិ ប្រយុទ្ធនិងជំងឺអេដស៍
- យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

មាត្រា ១ ._ តែងតាំង និងតំកល់ទុក ឯកឧត្តម ឆា ផលា ជាអគ្គលេខាធិការ នៃអាជ្ញាធរជាតិប្រយុទ្ធនឹង ជំងឺអេដស៍ នៅដដែលតាមស្មារតី នៃព្រះរាជក្រឹត្យលេខ នស/រកត/១០៩៩/១៥៨ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ ១៩៩៩ ដូចមានចែងក្នុងមូលបទខាងលើ ។

មាត្រា ២ ._ ឯកឧត្តម មាន ជីវុន អគ្គលេខាធិការនៃអាជ្ញាធរជាតិប្រយុទ្ធ នឹងជំងឺអេដស៍ តែងតាំងដោយព្រះរាជក្រឹត្យលេខ នស/រកត/០១០០/០០៧ ចុះថ្ងៃទី ១៣ ខែមករា ឆ្នាំ២០០០ ត្រូវបានផ្ទេរ ទៅកាន់ភារកិច្ចថ្មីតាមសំណើ របស់សាមីជន ។

មាត្រា ៣ ._ នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០០

ព្រះហស្តលេខា

**នរោត្តម សីហនុ**

**ព្រះរាជក្រឹត្យ នស/រកត/០៧០០/១២៧**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

****

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលត្រាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- យោងតាមសំណើរបស់សម្តេចប្រធានព្រឹទ្ធសភា ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០០

**ត្រាស់បង្គាប់**

មាត្រា ១ ._ តែងតាំងឯកឧត្តម គឹម សុខុន ជាទីប្រឹក្សាផ្ទាល់ឯកឧត្តម ញឹក ប៊ុនឆៃ អនុប្រធានទី ២ នៃព្រឹទ្ធសភា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

មាត្រា ២ ._ ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ ._ ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★

# ព្រះរាជក្រឹត្យ នស/រកត/០៧០០/១២៨

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

****

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលត្រាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី៨ ដល់ជំពូក ទី១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី០៤ ខែ មីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩៩ ត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- យោងតាមសំណើរបស់សម្តេចប្រធានព្រឹទ្ធសភា ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០០០

**ត្រាស់បង្គាប់**

មាត្រា ១ ._ តែងតាំងឯកឧត្តម ឈួន ចន្ទ ឆាយា ជាទីប្រឹក្សាផ្ទាល់ ឯកឧត្តម ញឹក ប៊ុនឆៃ អនុប្រធានទី២ នៃព្រឹទ្ធសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា ២ ._ ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ ._ ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ,ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០០

ព្រះហស្តលេខា

**នរោត្តម សីហនុ**

## ព្រះរាជក្រឹត្យ នស/រកត/០៧០០/១២៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

****

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ ១៩៩៥ បង្កើតគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំពីនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល

ត្រាស់បង្គាប់

មាត្រា ១ ._ មន្ត្រីរដ្ឋបាលជាន់ខ្ពស់ ចំនួន ១២ រូប នៃក្រសួងមហាផ្ទៃ ត្រូវបានទទួលការប្រោសព្រះរាជទាននូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់អស្សឫទ្ធិ ដូចមានរាយនាមខាងក្រោមនេះ :

១-ឯកឧត្តម ព្រំ សុខា រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ

២-ឯកឧត្តម នុត សារាន ទីប្រឹក្សាឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី

៣-ឯកឧត្តម ប្រាជ្ញ ចន្ទ អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ

៤-ឯកឧត្តម ហ៊ុន ណេង អភិបាល ខេត្តស្វាយរៀង

៥-ឯកឧត្តម ជា សុផារ៉ា ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ

៦-ឯកឧត្តម អ៊ុន សាមី អភិបាល ខេត្តពោធិសាត់

៧-ឯកឧត្តម ឡៅ អ៊ំ អភិបាល ខេត្តកំពង់ចាម

៨-ឯកឧត្តម ស៊ូ តិនិ អភិបាល ខេត្តកំពង់ឆ្នាំង

៩-ឯកឧត្តម ឡុយ សុផាត អភិបាល ខេត្តក្រចេះ

១០-ឯកឧត្តម ម៉ុល លីម ប្រធានក្រុមអ្នកច្បាប់ និងជាអគ្គាធិការរងទី១

១១-ឯកឧត្តម អ៊ុយ ស៊ីម ទីប្រឹក្សាឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជានាយករងខុទ្ទកាល័យក្រសួងមហាផ្ទៃ

១២-ឯកឧត្តម សត់ សេដ្ឋា អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ

មាត្រា ២ ._ នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលបន្ទុកអនុវត្ត អោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ ._ ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★

## ព្រះរាជក្រឹត្យ នស/រកត/០៧០០/១៣០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជា ធិរាជបរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

****

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២១ ខែកក្កដា ឆ្នាំ២០០០

## ត្រាស់បង្គាប់

មាត្រា ១ ._ ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក ហ្គុតប៊ី ហ្វ៊ីរីដុន (GHOTBI FERYDOON) សញ្ជាតិ អង់គ្លេស កើតថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ១៩៥៧ នៅក្រុង តេអេរ៉ង់ ប្រទេសអ៊ីរ៉ង់ ដោយយកឈ្មោះជាខ្មែរ ណៃ សុវណ្ណ ។

[មា]ត្រា ២ ._ នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ ._ ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០០

ព្រះហស្ថលេខា

នរោត្តម សីហនុ

★★★

ព្រះរាជក្រឹត្យ នស/រកត/០៧០០/១៣១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

****

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២១ ខែកក្កដា ឆ្នាំ២០០០

ត្រាស់បង្គាប់

មាត្រា ១ ._ ផ្តល់សញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍ជូនលោក (jsnick RUBELI) សញ្ជាតិដើមជា បារាំង កើតថ្ងៃទី០១ ខែកញ្ញា ឆ្នាំ ១៩៤៥ នៅ Momtreuil នៃប្រទេសបារាំង ។

មាត្រា ២ ._ នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ ._ ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០០

ព្រះហស្ថលេខា

នរោត្តម សីហនុ

★★★

# ព្រះរាជក្រឹត្យ នស/រកត/០៧០០/១៣២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

****

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ញាតិ
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២១ ខែកក្កដា ឆ្នាំ២០០០

## ត្រាស់បង្គាប់

**មាត្រា ១ .–** ផ្តល់សញ្ញាតិខ្មែរ តាមសញ្ញាតូបនីយកម្មជូនលោក យ៉ាំ ស៊ុយ សាំង (YUM SUI SANG) សញ្ញាតិដើមចិន កើតថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ ១៩៣៩ នៅទីក្រុង ហុងកុង ។

**មាត្រា ២ .–** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ .–** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

***

# ព្រះរាជក្រឹត្យ នស/រកត/០៧០០/១៣៣

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

****

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២១ ខែកក្កដា ឆ្នាំ២០០០

## ត្រាស់បង្គាប់

មាត្រា ១ ._ ត្រូវបានតែងតាំងមន្ត្រីរាជការជាន់ខ្ពស់ នៃក្រសួងសាធារណការ និងដឹកជញ្ជូន ដូចមានរាយនាមខាងក្រោម ៖

១-ឯកឧត្តម ស្លត សំបូរ ជាអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងសាធារណការនិងដឹកជញ្ជូន

២-ឯកឧត្តម ឡេង ធនយុទ្ធា ជាអគ្គនាយកនៃអគ្គនាយកដ្ឋានដឹកជញ្ជូននៃក្រសួងសាធារណការនិង ដឹកជញ្ជូន

មាត្រា ២ ._ បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយ និងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ ._ នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ ._ ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០០

ព្រះហស្តលេខា

**នរោត្តម សីហនុ**

***

# II- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យលេខ ៤៣ អនក្រ.បក
### ស្តីពីការបង្កើត វិទ្យាស្ថានគ្រប់គ្រងនិងសេដ្ឋកិច្ច

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើតនិងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- តាមសំណើរបស់ក្រសួងអប់រំ យុវជន និងកីឡា

### សំរេច

មាត្រា ១ ._ អនុញ្ញាតអោយបង្កើតវិទ្យាស្ថានឯកជនមួយ ដែលមានឈ្មោះថា វិទ្យាស្ថានគ្រប់គ្រង និងសេដ្ឋកិច្ច ( Institute of Management and Economy ) ហៅកាត់ " វ.គ.ស " ។ វិទ្យាស្ថាននេះ មានទីតាំងនៅអាគារលេខ ៥៥ ភូមិដំណាក់ហ្លួង ឃុំ វត្តគរ ស្រុក ស្វាយប៉ោ ខេត្តបាត់ដំបង ។

មាត្រា ២ ._ វិទ្យាស្ថាន គ្រប់គ្រង និងសេដ្ឋកិច្ច ធ្វើការ បណ្តុះបណ្តាល ថ្នាក់ បរិញ្ញាប័ត្រ ដោយមានរយៈពេលសិក្សា ៤ ឆ្នាំ ។

មាត្រា ៣ ._ វិទ្យាស្ថាន គ្រប់គ្រង និងសេដ្ឋកិច្ច មានមហាវិទ្យាល័យពីរ :

-មហាវិទ្យាល័យគ្រប់គ្រង

-មហាវិទ្យាល័យសេដ្ឋកិច្ច

ក្នុងវិទ្យាស្ថាននេះ មានផ្នែកបណ្តុះបណ្តាល ជំនាញ រយៈពេលខ្លី ដូចជា ជំនាញគណនេយ្យ កុំព្យូទ័រ និងភាសាអង់គ្លេស ។ ក្នុងពេលអនាគត វិទ្យាស្ថាន អាចបើកមហាវិទ្យាល័យ រឺ ជំនាញ ឯកទេសផ្សេងៗ ទៀត ដោយរៀបចំ សំណុំបែបបទ សុំការអនុញ្ញាតពី ក្រសួង អប់រំយុវជន និងកីឡា ។

មាត្រា ៤ ._ លក្ខខណ្ឌទទួលសិស្សអោយចូលរៀន :

-បេក្ខជនទាំងពីរភេទ ជា សិស្ស និស្សិត ប្រជាពលរដ្ឋ និង មន្ត្រីរាជការ

-បេក្ខជនត្រូវមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ឬ សញ្ញាប័ត្រដែលមានតំលៃស្មើ

-បេក្ខជនត្រូវឆ្លង កាត់ការ ប្រលងតេស្ត ។

មាត្រា ៥ ._ នាយក វិទ្យាស្ថាន គ្រប់គ្រង និងសេដ្ឋកិច្ច មានភារកិច្ច

-ជ្រើសរើសសិស្សអោយចូលរៀន និង ជ្រើសរើសសាស្ត្រាចារ្យមកបង្រៀន

-គ្រប់គ្រងអោយបានល្អនូវការបង្រៀនឯកសារសិក្សាការប្រលងនិងការប្រគល់សញ្ញាប័ត្រ

-គោរព និង អនុវត្ត តាមគោលការណ៍ និងសេចក្តីណែនាំ របស់រាជរដ្ឋាភិបាល

-ធានាអោយបាន នូវសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម

-ធ្វើរបាយការណ៍ រាល់សកម្មភាពសិក្សាជូន ក្រសួងអប់រំ យុវជន និងកីឡា ប្រចាំឆមាស និមួយៗ

មាត្រា ៦ ._ វិទ្យាស្ថានមានក្រុមប្រឹក្សាភិបាលមួយ ទទួលបន្ទុកគ្រប់គ្រងវិទ្យាស្ថាននេះ ។

មាត្រា ៧ ._ នៅក្នុងវិទ្យាស្ថាននេះ មានក្រុមប្រឹក្សាវិទ្យាសាស្ត្រ មួយ ដែលមានសមាជិកយ៉ាងតិច ៣ នាក់ ដែលមានសញ្ញាប័ត្រម៉ាស្ទ័រ យ៉ាងទាប ក្នុងមុខជំនាញ របស់វិទ្យាស្ថាន សំរាប់ពិនិត្យ និងផ្តល់ការយល់ព្រមលើ កម្មវិធីសិក្សា នៅដើមឆ្នាំ សិក្សានីមួយៗ ។

មាត្រា ៨ ._ ក្រសួងអប់រំ យុវជន និងកីឡា មានសិទ្ធិធ្វើ អធិការកិច្ច និងត្រួតពិនិត្យ លើការងារបណ្តុះបណ្តាល ហើយមានសិទ្ធិស្នើសុំបិទ ប្រសិនបើវិទ្យាស្ថាននេះអនុវត្តខុសពីច្បាប់រដ្ឋ ។

មាត្រា ៩ ._ និស្សិតដែលរៀនចប់កម្មវិធីសិក្សារបស់វិទ្យាស្ថាននេះ ហើយបានទទួលជោគជ័យ ក្នុងការប្រលងបញ្ចប់ការសិក្សា នឹងបានទទួលសញ្ញាប័ត្រ ថ្នាក់បរិញ្ញាប័ត្រ ដែលផ្តល់អោយដោយវិទ្យាស្ថាន គ្រប់គ្រង និង សេដ្ឋកិច្ចហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ដោយអនុវត្តតាម និយាមអប្បបរមា នៃការទទួលស្គាល់ គុណភាពបណ្តុះបណ្តាលកំរិតឧត្តមសិក្សា ។

មាត្រា ១០ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា អគ្គនាយកដ្ឋាន អង្គភាពពាក់ព័ន្ធ និង វិទ្យាស្ថានគ្រប់គ្រងនិងសេដ្ឋកិច្ច មានភារកិច្ចរៀងៗខ្លួនដើម្បីអនុវត្ត និង ប្រតិបត្តិតាមអនុក្រឹត្យនេះ ។

មាត្រា ១១ ._ អនុក្រឹត្យនេះមានប្រសិទ្ធភាព និង គតិយុត្ត ចាប់ពីថ្ងៃចុះ ហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃ ១៧ ខែ កក្កដា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

# អនុក្រឹត្យលេខ ៨៤ អនក្រ.បក
# ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ
# របស់រាជបណ្ឌិតសភាកម្ពុជា

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥៩៩/៩៧ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតគ្រឹះស្ថានសាធារណៈមួយដែលមានឧបនិស្ស័យវប្បធម៌ និងវិទ្យាសាស្ត្រមានឈ្មោះថា រាជបណ្ឌិតសភាកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមសំណើរមរបស់ចាំបាច់នៃការងារ ។

## សំរេច

## ជំពូកទី ១

## បទបញ្ញត្តិទូទៅ

**មាត្រា ១ .-**

អនុក្រឹត្យនេះកំណត់ការរៀបចំរចនាសម្ព័ន្ធ បេសកកម្ម តួនាទី ភារកិច្ចរបស់អង្គភាពនានានៃរាជបណ្ឌិតសភាកម្ពុជា ។

**មាត្រា ២ .-**

រាជបណ្ឌិតសភាកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសរបស់ទីស្តីការគណៈរដ្ឋមន្ត្រី និងនៅក្រោមអាណាព្យាបាលហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ២
## បេសកកម្ម និង ភារកិច្ច

មាត្រា ៣ .-

រាជបណ្ឌិតសភាកម្ពុជា ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាប្រគល់បេសកកម្ម អោយអភិវឌ្ឍកំលាំងបញ្ញាញាណនៃប្រជាជាតិកម្ពុជា ព្រមទាំងលើកទឹកចិត្ត ដឹកនាំ គ្រប់គ្រង់ ពង្រីកការស្រាវជ្រាវគ្រប់មុខជំនាញនៅក្នុងប្រទេស និងស្ថាបនាទំនាក់ទំនងសហប្រតិបត្តិការផ្នែកស្រាវជ្រាវជាមួយអង្គការជាតិនិងអន្តរជាតិដែលមានគោលបំណងដូចគ្នា ។

ក្នុងន័យនេះ រាជបណ្ឌិតសភាកម្ពុជាមានភារកិច្ច ដូចតទៅ :

-គ្រប់គ្រង និងពង្រីកការស្រាវជ្រាវខេមរវិទ្យា និងគ្រប់មុខជំនាញនៅក្នុងប្រទេស

-ស្ថាបនាទំនាក់ទំនងសហប្រតិបត្តិការផ្នែកស្រាវជ្រាវជាមួយក្រសួង ស្ថាប័ន អង្គការជាតិ និងអន្តរជាតិ ដែលមានគោលបំណងដូចគ្នា

-រៀបចំវេទិកាវិទ្យាសាស្ត្រ និងអប់រំ ដើម្បីជួយអភិវឌ្ឍប្រទេសលើគ្រប់វិស័យ

-បណ្តុះបណ្តាលថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ ( Master ) និងថ្នាក់បណ្ឌិត ( Ph.D )

-បោះពុម្ពផ្សាយឯកសារ ស្នាដៃស្រាវជ្រាវ និងរបកគំហើញ ជាភាសាជាតិ អោយបានទូលំទូលាយដល់មហាជននៅក្នុងប្រទេស និងជាភាសាបរទេស ដើម្បីផ្សព្វផ្សាយខេមរវិទ្យា នៅលើវេទិកាអន្តរជាតិ

-ប្រមូល និងតំកល់ឯកសារស្រាវជ្រាវអំពីប្រទេសកម្ពុជា អំពីបណ្តាប្រទេសនៅក្នុងតំបន់ និងលើពិភពលោក

-ប្រមូលកំលាំងបញ្ញាញាណរបស់ជាតិ ដើម្បីជំរុញការអភិវឌ្ឍន៍ប្រទេសអោយបានឆាប់រហ័ស

-លើកសំណើ ជូនគ្រឿងឥស្សរិយយសវិទ្យាសាស្ត្រ ដល់ឥស្សរជនឆ្នើមជាតិ និងអន្តរជាតិ

-សហការពិនិត្យ និងវាយតំលៃសញ្ញាប័ត្រឧត្តមសិក្សា និងក្រោយឧត្តមសិក្សា

-ចូលរួមចំណែក និង ធ្វើសហប្រតិបត្តិការក្នុងការការពារកម្មសិទ្ធិខាងផ្នែកវិទ្យាសាស្ត្រគ្រប់វិស័យ

-ពិនិត្យ និងវាយតំលៃស្នាដៃស្រាវជ្រាវវិទ្យាសាស្ត្រ

-ពិនិត្យ និងវាយតំលៃការវិវត្តន៍សង្គម និងរួមវិភាគទានជំរុញការអភិវឌ្ឍន៍

-សហការរួមចំណែករៀបចំ វិទ្យាស្ថានស្រាវជ្រាវផ្នែកជំនាញ តាមក្រសួងនានា

-បង្កើត និងគ្រប់គ្រង សាខានៃរាជបណ្ឌិតសភាកម្ពុជា នៅតាមភូមិភាគនានានៃប្រទេស

-សហការជាមួយក្រសួងដែលពាក់ព័ន្ធ ដើម្បីជួយបង្កើត និងដឹកនាំការគ្រប់គ្រង សារមន្ទីរប្រវត្តិសាស្ត្រ និងប្រវត្តិសាស្ត្រ នៅតាមខេត្ត ក្រុង ។

## ជំពូកទី ៣
## ការគ្រប់គ្រង និង រដ្ឋបាល
### ផ្នែកទី ១
### គណៈកម្មាធិការប្រតិបត្តិ

មាត្រា ៤ .-

៤.១. រាជបណ្ឌិត្យសភាកម្ពុជាត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាល ។ ក្រុមប្រឹក្សាភិបាលត្រូវរៀបចំការបោះឆ្នោតជ្រើសតាំងគណៈកម្មាធិការប្រតិបត្តិមួយឲ្យដឹកនាំ និងគ្រប់គ្រងការងារប្រចាំថ្ងៃ ។ គណៈកម្មាធិការប្រតិបត្តិទទួលសិទ្ធិយ៉ាងពេញលេញក្នុងការបំពេញការងារ លើកលែងតែភារកិច្ចរបស់ក្រុមប្រឹក្សាភិបាល ដែលមានចែងក្នុងមាត្រា ៩ នៃព្រះរាជក្រឹត្យស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា ។

៤.២. គណៈកម្មាធិការប្រតិបត្តិការទទួលបន្ទុក ដូចតទៅ :

-ប្រធាន ឋានៈស្មើរដ្ឋលេខាធិការ ទទួលខុសត្រូវរួម

-សមាជិកមួយនាក់ ឋានៈស្មើអនុរដ្ឋលេខាធិការ ទទួលបន្ទុកជាអគ្គលេខាធិការ

-សមាជិកមួយនាក់ ឋានៈស្មើអនុរដ្ឋលេខាធិការ ទទួលបន្ទុកពីរវិទ្យាស្ថាន :

- វិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ
- វិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម

-សមាជិកមួយនាក់ ឋានៈស្មើអនុរដ្ឋលេខាធិការ ទទួលបន្ទុកពីរវិទ្យាស្ថាន :

- វិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រ និងកសិកម្ម
- វិទ្យាស្ថានវិទ្យាសាស្ត្រ និងបច្ចេកទេសវិទ្យា

ដោយឡែក អនុប្រធានក្រុមប្រឹក្សាភិបាលដែលជាប្រធានវិទ្យាស្ថានភាសាជាតិ មានឋានៈស្មើអនុរដ្ឋលេខាធិការ ទទួលបន្ទុកវិទ្យាស្ថានភាសាជាតិ ។

៤.៣. សមាជិកគណៈកម្មាធិការប្រតិបត្តិ និងប្រធានវិទ្យាស្ថានភាសាជាតិ មានភារកិច្ច :

-ទទួលកម្មវិធីការងារពីគណៈកម្មាធិការប្រតិបត្តិ តាមរយៈអគ្គលេខាធិការដ្ឋាន ដើម្បីដាក់ជូនវិទ្យាស្ថានអនុវត្ត

-សរុបការងារអនុវត្ត និងគំរោងផែនការរបស់វិទ្យាស្ថានក្រោមឱវាទ ដាក់ជូនគណៈកម្មាធិការប្រតិបត្តិ តាមរយៈអគ្គលេខាធិការដ្ឋាន ដើម្បីពិនិត្យ និងសំរេច

-ជំរុញការអភិវឌ្ឍន៍វិទ្យាស្ថាន និងផ្នែកជំនាញនានា នៅក្រោមឱវាទ ។

### ផ្នែកទី ២
### សេនាធិការ

មាត្រា ៥ .-

គណៈកម្មាធិការប្រតិបត្តិការមានសេនាធិការ ដូចខាងក្រោម :

ក-ខុទ្ទកាល័យ

ខុទ្ទកាល័យរបស់ប្រធានរាជបណ្ឌិត្យសភាកម្ពុជាត្រូវដឹកនាំដោយនាយខុទ្ទកាល័យមួយរូប និងមាននាយរងខុទ្ទកាល័យមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

នាយខុទ្ទកាល័យមានឋានៈស្មើអនុប្រធាននាយកដ្ឋាន ។ នាយរងខុទ្ទកាល័យមានឋានៈស្មើប្រធានការិយាល័យ ។

ខ-អគ្គលេខាធិការដ្ឋាន

អគ្គលេខាធិការដ្ឋានទទួលបន្ទុកដោយអគ្គលេខាធិការមួយរូប និងមានអគ្គលេខាធិការរងពីររូបជាជំនួយដែលមានឋានៈស្មើអគ្គនាយក ។

មាត្រា ៦.-

អគ្គលេខាធិការដ្ឋាន ដែលជាអង្គភាពរដ្ឋបាលរបស់គណៈកម្មាធិការប្រតិបត្តិ មានភារកិច្ច ៖

-ទទួលកម្មវិធីការងារពីគណៈកម្មាធិការប្រតិបត្តិ ដើម្បីដាក់ជូនអង្គភាពក្រោមឱវាទអនុវត្ត

-ទទួលសំណើពីអង្គភាពក្រោមឱវាទ ដើម្បីដាក់ជូនគណៈកម្មាធិការប្រតិបត្តិពិនិត្យនិង សំរេច

-ចាត់ចែងកិច្ចការទូទៅក្នុងរាជបណ្ឌិត្យសភាកម្ពុជា និងរៀបចំសំណុំឯកសារផ្សេងៗ ដាក់ជូនគណៈកម្មាធិការប្រតិបត្តិ

-រៀបចំជូនគណៈកម្មាធិការប្រតិបត្តិ នូវរបៀបវារៈនៃការប្រជុំ និងមហាសន្និបាតនៃរាជបណ្ឌិត្យសភាកម្ពុជា ព្រមទាំងធ្វើកំណត់ហេតុ និងធ្វើរបាយការណ៍

-រៀបចំបំពាក់សំភារៈបរិក្ខារដល់រាជបណ្ឌិត្យសភាកម្ពុជា តាមការអនុញ្ញាតពីគណៈកម្មាធិការប្រតិបត្តិ

-ធ្វើរបាយការណ៍រៀងរាល់ខែកញ្ញា ស្ដីពីសកម្មភាពកន្លងមកនៃរាជបណ្ឌិត្យសភាកម្ពុជា ដើម្បីដាក់ជូនគណៈកម្មាធិការប្រតិបត្តិ

-អគ្គលេខាធិការដ្ឋានមានបួនផ្នែក ៖

- ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ
- ផ្នែកផែនការ និងទំនាក់ទំនងសាធារណៈ
- ផ្នែកបណ្ដុះបណ្ដាល និងស្រាវជ្រាវ
- ផ្នែកបោះពុម្ពផ្សាយ ។

មាត្រា ៧.-

ផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ និងផ្នែកផែនការនិងទំនាក់ទំនងសាធារណៈត្រូវដឹកនាំដោយអគ្គលេខាធិការរងទី១ ដែលមានភារកិច្ចប្រមូលសរុបការងារទូទៅនៃផ្នែកជំនាញនៅក្រោមឱវាទ ដាក់ជូនអគ្គលេខាធិការ ។ ផ្នែកបណ្ដុះបណ្ដាល និងស្រាវជ្រាវ និងផ្នែកបោះពុម្ពផ្សាយ ត្រូវដឹកនាំដោយអគ្គលេខាធិការរង

ទី២ដែលមានភារកិច្ចប្រមូលសរុបការងារទូទៅនៃផ្នែកបណ្តុះបណ្តាល និងស្រាវជ្រាវ និងផ្នែកបោះពុម្ពផ្សាយ ដាក់ជូន អគ្គលេខាធិការ ។

ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ ដែលមានឋានៈស្មើនាយកដ្ឋាន មានភារកិច្ច ៖

-ទទួលខុសត្រូវផ្នែករដ្ឋបាល ហិរញ្ញវត្ថុ និងការផ្គត់ផ្គង់

-រៀបចំសំណុំលិខិតរដ្ឋបាល និងហិរញ្ញវត្ថុ

-ការពារសន្តិសុខ សណ្តាប់ធ្នាប់ រក្សាសុវត្ថិភាពសម្ភារៈ និងអនាម័យ

-គ្រប់គ្រងសំណុំលិខិតមន្ត្រី បុគ្គលិក រៀបចំប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ

-រៀបចំគំរោងថវិកា គំរោងសម្ភារៈបរិក្ខារ និងមធ្យោបាយការងារផ្សេងៗ

-គ្រប់គ្រងអចលនទ្រព្យ ចលនទ្រព្យ និងការចំណូល ចំណាយរបស់ស្ថាប័ន ។

មាត្រា ៨ ._

ផ្នែកផែនការ និងទំនាក់ទំនងសាធារណៈ ដែលមានឋានៈស្មើនាយកដ្ឋាន មានភារកិច្ច ៖

-កសាងផែនការគោល លើគ្រប់ផ្នែករបស់ស្ថាប័ន

-រៀបចំ និងគ្រប់គ្រងប្រព័ន្ធទិន្នន័យរបស់ស្ថាប័ន

-ធ្វើកម្មវិធីសហប្រតិបត្តិការជាមួយស្ថាប័នស្រាវជ្រាវ ព្រមទាំងអង្គការជាតិ និងអន្តរជាតិ

-សំរបសំរួលជំនួយនានា គ្រប់គ្រងវាយតំលៃ និងត្រួតពិនិត្យការអនុវត្តន៍គំរោងនានាទាំងផ្នែកបច្ចេកទេស ទាំងផ្នែកហិរញ្ញវត្ថុ

-ទាក់ទងជាមួយក្រសួង អង្គការជាតិ និងអន្តរជាតិនានា ដើម្បីអភិវឌ្ឍវិស័យស្រាវជ្រាវ សំរបសំរួលការងារជាមួយស្ថាប័ននានា និងការងារអន្តរជាតិ

-គ្រប់គ្រងរាល់ឯកសារសហប្រតិបត្តិការ

-គ្រប់គ្រងបែបបទ សំណុំលិខិតអ្នកស្រាវជ្រាវ និងមន្ត្រីរាជបណ្ឌិត្យសភាកម្ពុជា ដែលទៅបំពេញបេសកកម្មនៅបរទេស

-ជ្រើសរើស និងគ្រប់គ្រងនិស្សិតអាហារូបករណ៍ និងកម្មសិក្សាការី ដែលទៅសិក្សានៅបរទេស

-រៀបចំចុះបញ្ជីតំកល់ចំណងជើងកិច្ចការស្រាវជ្រាវពីថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ឡើងទៅ ។

មាត្រា ៩ ._

ផ្នែកបណ្តុះបណ្តាល និងស្រាវជ្រាវ ដែលមានឋានៈស្មើនាយកដ្ឋាន មានភារកិច្ច ៖

-ស្វែងយល់អំពីកម្មវិធី និងខ្លឹមសារនៃការបណ្តុះបណ្តាលថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិតក្នុងតំបន់ និងលើពិភពលោក

-រៀបចំគំរោងបណ្តុះបណ្តាលថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ ( Master ) និងថ្នាក់បណ្ឌិត ( Ph.D )

-គ្រប់គ្រង និងសំរបសំរួលកម្មវិធី និងខ្លឹមសារនៃការបណ្តុះបណ្តាលថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ ( Master ) និងថ្នាក់បណ្ឌិត ( Ph.D )

-រៀបចំកម្មវិធី ប្រលងប្រជែងជ្រើសរើសនិស្សិតសំរាប់ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ ( Master ) និងថ្នាក់បណ្ឌិត ( Ph.D )

-ស្វែងយល់អំពីស្ថាប័នស្រាវជ្រាវនៅក្នុង និងក្រៅប្រទេស

-រៀបចំទំនាក់ទំនងផ្នែកស្រាវជ្រាវជាមួយស្ថាប័នខាងលើ

-គ្រប់គ្រង និងសំរបសំរួលការស្រាវជ្រាវនៅក្នុងប្រទេស

-ចាត់ចែង និងរៀបចំកិច្ចការបកប្រែ ។

មាត្រា ១០ ._

ផ្នែកបោះពុម្ពផ្សាយ ដែលមានឋានៈស្មើអនុប្រធាននាយកដ្ឋាន មានភារកិច្ច :

-ពិនិត្យអត្ថបទស្រាវជ្រាវគ្រប់ផ្នែក នៃវិទ្យាស្ថានក្រោមឱវាទរាជបណ្ឌិតសភាកម្ពុជា

-ពិនិត្យអត្ថបទបកប្រែគ្រប់ផ្នែក នៃវិទ្យាស្ថានក្រោមឱវាទរាជបណ្ឌិតសភាកម្ពុជា

-រៀបចំរោងបោះពុម្ពផ្សាយ និងចាត់ចែងការបោះពុម្ពផ្សាយអត្ថបទខាងលើ

-ចាត់ចែងការចែកផ្សាយស្នាដៃបោះពុម្ពរបស់រាជបណ្ឌិតសភាកម្ពុជា

-ប្រមូលស្នាដៃស្រាវជ្រាវជាន់ខ្ពស់គ្រប់ផ្នែកនៅក្នុង និងក្រៅប្រទេស សំរាប់តំកល់ទុកក្នុងបណ្ណាល័យនៃរាជបណ្ឌិតសភាកម្ពុជា

-គ្រប់គ្រងបណ្ណាល័យនៃរាជបណ្ឌិតសភាកម្ពុជា ។

## ជំពូកទី ៤

## ស្ថាប័នឧបសម្ព័ន្ធនៃរាជបណ្ឌិតសភាកម្ពុជា

### ផ្នែកទី ១

### វិទ្យាស្ថាន

មាត្រា ១១ ._

តាមមាត្រា២០ នៃព្រះរាជក្រឹត្យ រាជបណ្ឌិតសភាកម្ពុជាមានវិទ្យាស្ថានចំនួនប្រាំ ។ វិទ្យាស្ថាននីមួយៗ មានឋានៈស្មើអគ្គនាយកដ្ឋាន ហើយផ្នែកនីមួយៗនៃវិទ្យាស្ថានមានឋានៈស្មើនាយកដ្ឋាន ។

មាត្រា ១២ ._

វិទ្យាស្ថានទាំងប្រាំ ដែលជាស្ថាប័នឧបសម្ព័ន្ធនៃរាជបណ្ឌិតសភាកម្ពុជា មានភារកិច្ច :

-អនុវត្តកិច្ចការតាមការណែនាំរបស់គណៈកម្មាធិការប្រតិបត្តិ

-គ្រប់គ្រង និងអភិវឌ្ឍផ្នែកជំនាញនៅក្រោមឱវាទ

-លើកគំរោងហិរញ្ញវត្ថុ ផែនការ បណ្តុះបណ្តាល ស្រាវជ្រាវ និងបោះពុម្ពផ្សាយ ដោយសហការជាមួយផ្នែកជំនាញ ។

មាត្រា ១៣ ._

វិទ្យាស្ថាននីមួយៗមានស្វ័យភាពក្នុងការគ្រប់គ្រងផ្ទៃក្នុង និងប្រើប្រាស់ថវិកាដែលស្ថិតនៅក្នុងជំពូករបស់ខ្លួនផ្ទាល់ ។

មាត្រា ១៤ ._

សមាសភាព និងឋានៈនៃគណៈគ្រប់គ្រងវិទ្យាស្ថាន :

-ប្រធានវិទ្យាស្ថាន ថ្នាក់បណ្ឌិត មានឋានៈស្មើអគ្គនាយក

-អនុប្រធានវិទ្យាស្ថាន ថ្នាក់បណ្ឌិត មានឋានៈស្មើអគ្គនាយករង

-លេខាធិការដ្ឋាន ថ្នាក់បណ្ឌិត ឬបរិញ្ញាប័ត្រជាន់ខ្ពស់ ឬបរិញ្ញាប័ត្រ មានឋានៈស្មើប្រធាននាយកដ្ឋាន

-ប្រធានផ្នែកជំនាញ ថ្នាក់បណ្ឌិត ឬបរិញ្ញាប័ត្រជាន់ខ្ពស់ ឬបរិញ្ញាប័ត្រ មានឋានៈស្មើប្រធាននាយកដ្ឋាន ។

## ផ្នែកទី ២

## សាខារបស់រាជបណ្ឌិតសភាកម្ពុជានៅតាមភូមិភាគ

មាត្រា ១៥ ._

រាជបណ្ឌិតសភាកម្ពុជាអាចមានសាខានៅតាមភូមិភាគនានា ដើម្បីជួយជំរុញការអភិវឌ្ឍន៍លើគ្រប់វិស័យនៅលើផ្ទៃប្រទេសទាំងមូល ។

តួនាទី និង ភារកិច្ច នៃសាខារាជបណ្ឌិតសភាកម្ពុជានៅតាមភូមិភាគ ត្រូវកំណត់ដោយប្រកាសរបស់រាជបណ្ឌិតសភាកម្ពុជា ។

## ផ្នែកទី ៣

## សារមន្ទីរបុរេប្រវត្តិសាស្ត្រ និង ប្រវត្តិសាស្ត្រ

មាត្រា ១៦ ._

សារមន្ទីរបុរេប្រវត្តិសាស្ត្រ និងប្រវត្តិសាស្ត្រដែលជាកន្លែងតាំងពិព័រណ៍ វត្ថុពិពិធ ឧបករណ៍ សិល្បៈ ។ល។ ពីសម័យមុន និងសម័យដែលប្រវត្តិសាស្ត្រតាមភូមិភាគ អាចមាននៅគ្រប់ខេត្ត ក្រុង ក្នុងប្រទេស ។ សារមន្ទីរនេះដែលជានិមិត្តរូបនៃមោទនភាពខេត្ត ក្រុង ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងផ្នែកបច្ចេកទេស ពីរាជបណ្ឌិតសភាកម្ពុជា ។

## ជំពូកទី ៥

## បុគ្គលិករាជបណ្ឌិតសភាកម្ពុជា

មាត្រា ១៧ ._

១៧.១ បុគ្គលិករដ្ឋបាលរបស់រាជបណ្ឌិតសភាកម្ពុជា រួមមានមន្ត្រីរាជការដែលត្រូវបានតែងតាំង ឬផ្ទេរបញ្ជូនមកបំពេញការងារនៅក្នុងរាជបណ្ឌិតសភាកម្ពុជា ដោយអនុលោមតាមបទបញ្ញត្តិទាំងឡាយនៃច្បាប់ និងអត្តបទពាក់ព័ន្ធដទៃទៀតរបស់មន្ត្រីរាជការ ។

១៧.២ អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រាជបណ្ឌិតសភាកម្ពុជា អាចឲ្យរាជបណ្ឌិតសភាកម្ពុជាជ្រើសរើសបុគ្គលិកក្រៅក្របខ័ណ្ឌនៃមុខងារសាធារណៈ តាមរបបកិច្ចសន្យា ដើម្បី

បំពេញការងារពិសេសណាមួយ ។ បុគ្គលិកទាំងនេះ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងនៃបទបញ្ញាផ្ទៃក្នុង និងតាមសេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល ស្របតាមច្បាប់ស្តីពីការងារ ។

១៧.៣ បុគ្គលិករបស់រាជបណ្ឌិតសភាកម្ពុជា ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង នៃបទបញ្ញាស្តីពីបុគ្គលិកដែលសំរេចដោយក្រុមប្រឹក្សាភិបាល ។ ចំពោះមន្ត្រីរាជការនៃមុខងារសាធារណៈ បទបញ្ញាស្តីពីបុគ្គលិកនេះមិនត្រូវផ្ទុយពីបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ និងអត្ថបទពាក់ព័ន្ធដទៃទៀតរបស់មន្ត្រីរាជការឡើយ ។

## ជំពូកទី ៦

## ទ្រព្យសម្បត្តិរបស់រាជបណ្ឌិតសភាកម្ពុជា

មាត្រា ១៨ ._

១៨.១ រាជបណ្ឌិតសភាកម្ពុជាត្រូវទទួលគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ តាមលក្ខខណ្ឌកំណត់ក្នុងបទប្បញ្ញត្តិទាំងឡាយស្តីពីបញ្ហានេះ ។

១៨.២ រាជបណ្ឌិតសភាកម្ពុជាអាចមានថវិកា និងទ្រព្យសម្បត្តិផ្ទាល់ខ្លួន ហើយអាចទទួលយកអំណោយនិងអករតចពីសប្បុរសជនជាតិ និងអន្តរជាតិ សំរាប់ផលប្រយោជន៍រួម ។

## ជំពូកទី ៧

## ការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ និង គណនេយ្យ

មាត្រា ១៩ ._

លើកលែងតែមានបទបញ្ញត្តិដោយឡែក ដែលមានចែងក្នុងព្រះរាជក្រឹត្យស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា រាជបណ្ឌិតសភាកម្ពុជាត្រូវស្ថិតនៅក្រោមគោលការណ៍ នៃគណនេយ្យសាធារណៈលើការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ និងគណនេយ្យ ដូចដែលមានកំណត់ក្នុងមាត្រា ១២២ នៃអនុក្រឹត្យលេខ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ ។

មាត្រា ២០ ._

២០.១ ប្រធានរាជបណ្ឌិតសភា ជាអាណាប័កដើមខ្សែរបស់រាជបណ្ឌិតសភាកម្ពុជា ។ ក្នុងន័យនេះ ដើម្បីអនុលោមតាមបទបញ្ញាផ្ទៃក្នុងរបស់រាជបណ្ឌិតសភាកម្ពុជា ប្រធានត្រូវមានភារកិច្ច :

-ពិនិត្យប្រាក់ និងទូទាត់ចំណូល

-ចាត់ចែងធ្វើការទូទាត់ និងចេញបញ្ជាចំណាយ

២០.២. អាណាប័កដើមខ្សែអាចផ្ទេរសិទ្ធិឲ្យអាណាប័កផ្ទេរសិទ្ធិ ឬ បង្កើតដោយមានការព្រមព្រៀង ពីគណនេយ្យករ នូវរដ្ឋទេយ្យចំណូល ឬបុរេប្រទាន ។

មាត្រា ២១ ._

២១.១. ប្រតិបត្តិការហិរញ្ញវត្ថុ និងការកាន់កាប់គណនេយ្យ ត្រូវអនុវត្តដោយអនុលោមតាមបទបញ្ញាផ្ទៃក្នុងរបស់រាជបណ្ឌិតសភាកម្ពុជា ក្រោមការទទួលខុសត្រូវផ្ទាល់របស់គណនេយ្យករ ។

គណនេយ្យករនេះ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់ការងារ ។ គណនេយ្យករនេះ ត្រូវចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សាភិបាលក្នុងឋានៈជាអ្នកពិគ្រោះយោបល់ ។

ព្រះរាជក្រឹត្យស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា អាចគ្រោងនូវការតែងតាំងគណនេយ្យករជាអ្នកទទួលខុសត្រូវលើវណ្ណៈអង្គភាពហិរញ្ញវត្ថុរបស់រាជបណ្ឌិតសភាកម្ពុជា ។ ក្នុងមុខតំណែងនេះ គណនេយ្យករត្រូវស្ថិតក្រោមឱវាទផ្ទាល់របស់ប្រធាន ។

២១.២. គណនេយ្យករ មានភារកិច្ច :

-ប្រមូលចំណូល

-បើកប្រាក់ចំណាយ

-រក្សាទុក និងចាត់ចែងប្រើប្រាស់មូលនិធិ និងវត្ថុមានតំលៃ

-រក្សាទុកលិខិតយុត្តការណ៍ និងកាន់កាប់បញ្ជីគណនេយ្យ

២១.៣. គណនេយ្យករ អាចផ្ទេរសិទ្ធិខ្លះឲ្យទៅមន្ត្រីក្នុងការិយាល័យ ។

## ជំពូកទី ៨

## របបសារពើពន្ធនៃរាជបណ្ឌិតសភាកម្ពុជា

**មាត្រា ២២ .-**

លើកលែងតែមានបដិបញ្ញត្តិដែលចែងដោយច្បាប់ រាជបណ្ឌិតសភាកម្ពុជាត្រូវស្ថិតនៅក្រោមនិតិរួមចំពោះរបបសារពើពន្ធ ដូចដែលត្រូវបានអនុវត្តលើអង្គភាពនានារបស់រដ្ឋ ។

## ជំពូកទី ៩

## រូបសញ្ញា និងត្រា

**មាត្រា ២៣ .-**

រាជបណ្ឌិតសភាកម្ពុជា មានរូបសញ្ញា និងត្រាដោយឡែករបស់ខ្លួន ។

## ជំពូកទី ១០

## អាណាព្យាបាលភាព

**មាត្រា ២៤ .-**

រាជបណ្ឌិតសភាកម្ពុជា ត្រូវស្ថិតនៅក្រោម :

១. អាណាព្យាបាលបច្ចេកទេសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដែលទទួលបន្ទុកផ្នែកសកម្មភាពនៃរាជបណ្ឌិតសភាកម្ពុជា

២.អាណាព្យាបាលហិរញ្ញវត្ថុរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ២៥ .-

អាជ្ញាធរអាណាព្យាបាលអាចចាត់មន្ត្រីឲ្យធ្វើអធិការកិច្ច ឬត្រួតពិនិត្យ បើឃើញថាជាការចាំបាច់ ។

មាត្រា ២៦ .-

២៦.១. រាជបណ្ឌិត្យសភាកម្ពុជា ត្រូវផ្តល់ជូនគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដែលមានចែងក្នុងមាត្រា ៣៤ ខាងក្រោមនេះនូវឯកសារដូចតទៅ :

-កំណត់ហេតុនៃការប្រជុំរបស់ក្រុមប្រឹក្សាភិបាល

-ផែនការពង្រីកគ្រឹះស្ថាន

-ថវិកាប្រចាំឆ្នាំ

-របាយការណ៍ស្តីពីការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ ។

២៦.២. ឯកសារទាំងនេះ ត្រូវបញ្ជូនទៅអ្នកដែលត្រូវទទួលក្នុងរយៈពេលមិនឲ្យហួសពី១៥ ថ្ងៃ ។

## ផ្នែកទី ១

## អាណាព្យាបាលបច្ចេកទេស

មាត្រា ២៧ .-

២៧.១. ក្នុងរយៈពេល១៥ ថ្ងៃ បន្ទាប់ពីការប្រជុំក្រុមប្រឹក្សាភិបាល ប្រធានរាជបណ្ឌិត្យសភាកម្ពុជា ត្រូវផ្ញើជូនរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវកម្មវិធីអភិវឌ្ឍន៍ និងគំរោងថវិការដើម្បីសុំការយល់ព្រម ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានពេល១ខែ គិតចាប់ពីថ្ងៃ ដែលបានទទួលឯកសារ ត្រូវរៀបចំយោបល់របស់ខ្លួនជូនរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីមានពេល២ខែ គិតចាប់ពីថ្ងៃដែលបានទទួលឯកសារ ដែលបញ្ជូនដោយប្រធានរាជបណ្ឌិត្យសភាកម្ពុជា ដើម្បីសំរេចផ្តល់ការយល់ព្រមលើឯកសារទាំងនោះ ។

២៧.២. លិខិតយល់ព្រម ត្រូវចុះហត្ថលេខាត្រឹមត្រូវដោយរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ឬអ្នកតំណាង ហើយត្រូវផ្ញើជូនប្រធានរាជបណ្ឌិត្យសភាកម្ពុជា ដោយមានចំលងជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ប្រធានរាជបណ្ឌិត្យសភាកម្ពុជាត្រូវជូនព័ត៌មាននេះទៅក្រុមប្រឹក្សាភិបាលលើកក្រោយបំផុត ។

ក្នុងករណីដែល រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី មិនបានធ្វើការតបតាមរយៈពេលកំណត់ទេនោះកម្មវិធីអភិវឌ្ឍន៍ ឬគំរោងថវិកា ត្រូវចាត់ទុកថាបានទទួលការឯកភាព ។

ប្រសិនបើរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី បានធ្វើការជំទាស់លើកម្មវិធីអភិវឌ្ឍន៍ ឬគំរោងថវិកានេះ ប្រធានក្រុមប្រឹក្សាភិបាល ត្រូវរៀបចំការប្រជុំក្រុមប្រឹក្សាភិបាលជាបន្ទាន់ ដើម្បីពិភាក្សា និងរិះរកមធ្យោបាយសំរាប់ដោះស្រាយការជំទាស់ទាំងនេះ ។

កម្មវិធីអភិវឌ្ឍន៍ និងថវិកាចំណាយជាមូលធនមិនអាចដាក់ឲ្យអនុវត្តបានឡើយ ក្នុងករណីដែលការជំទាស់លើកឡើងដោយរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ពុំទាន់ត្រូវបានដោះស្រាយរួចនៅឡើយនោះ ។

ថវិកាចំណាយជាប្រចាំ អាចដាក់ឲ្យអនុវត្តត្រឹមលំនាំប្រព័ន្ធបំបែកជា "ជាប់ពីរ" ប៉ុណ្ណោះនៅពេលដែលនៅមានការជំទាស់ពីរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ២៨ .-**

២៨.១. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងក្របខ័ណ្ឌនៃសិទ្ធិធ្វើការជំទាស់របស់ខ្លួនអាចលើកឡើងនូវការជំទាស់លើឯកសារ ដែលត្រូវបានបញ្ជូនមកខ្លួនដូចមានចែងក្នុងមាត្រា ២៧ ខាងលើមាន : កំណត់ហេតុប្រជុំរបស់ក្រុមប្រឹក្សាភិបាល របាយការណ៍លើការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ ។ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីមានរយៈពេលមួយខែសំរាប់លើកឡើងនូវការជំទាស់ទាំងនោះ ។

២៨.២. ប្រធានរាជបណ្ឌិត្យសភាកម្ពុជា ត្រូវជំរាបជូនដល់ក្រុមប្រឹក្សាភិបាលនូវខ្លឹមសារនៃការជំទាស់ដែលបានលើកឡើងដោយរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។

ក្រុមប្រឹក្សាភិបាល ត្រូវធ្វើការពិភាក្សាឲ្យបានឆាប់បំផុត លើការជំទាស់របស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរិះរកមធ្យោបាយសំរាប់ដោះស្រាយការជំទាស់ទាំងនោះ ។ ប្រសិនបើក្រុមប្រឹក្សាភិបាលសំរេចមិនយល់ស្របនឹងការជំទាស់ទាំងនោះ សេចក្តីសំរេចនេះត្រូវបញ្ជាក់ពីមូលហេតុ ហើយត្រូវជំរាបជូនដំណឹងជាបន្ទាន់ស្តីពីបញ្ហានេះ ជាលាយលក្ខណ៍អក្សរដល់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ២៩ .-**

២៩.១. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អាចធ្វើការលុប ឬផ្អាកទុកនូវសេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល និងប្រធានរាជបណ្ឌិត្យសភាកម្ពុជា ក្នុងករណីដែលសេចក្តីសំរេចនោះ :

-ផ្ទុយនឹងគោលដៅរបស់រាជបណ្ឌិត្យសភាកម្ពុជា

-ផ្ទុយនឹងច្បាប់ និងបទបញ្ជា

-ធ្វើឡើងដោយអាជ្ញាធរមួយដែលមិនមានសិទ្ធិសំរេច ឬធ្វើឡើងដោយការប្រជុំពុំស្របច្បាប់របស់ក្រុមប្រឹក្សាភិបាល ។

២៩.២. ការលុបចោល ឬការផ្អាកទុកនេះ ត្រូវសំរេចឡើងតាមរយៈប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដោយមានបញ្ជាក់ពីមូលហេតុតាមគំនិតផ្ទាល់ខ្លួន ឬតាមបណ្តឹងពីភាគីនានាដែលពាក់ព័ន្ធ ។ ការលុបចោល ឬការផ្អាកទុកនូវសេចក្តីសំរេចនេះ ត្រូវជូនដំណឹងដល់ប្រធានរាជបណ្ឌិត្យសភាកម្ពុជា ហើយប្រធានត្រូវជូនពត៌មានបន្តទៅក្រុមប្រឹក្សាភិបាល ក្នុងរយៈពេលដ៏ឆាប់បំផុត ។

មាត្រា ៣០ ._

ក្នុងករណីដែលក្រុមប្រឹក្សាភិបាល និងប្រធាន ពុំប្រតិបត្តិតាមបញ្ញត្តិនានា ដែលមានចែងក្នុងអត្ថបទច្បាប់ ឬបទបញ្ញត្តិ និងបទបញ្ជាផ្ទៃក្នុងរបស់បណ្ឌិតសភាកម្ពុជា រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី បន្ទាប់ពីធ្វើការណែនាំ និងដាក់កំហិតជាលាយលក្ខណ៍អក្សរហើយ អាចចាត់ចែងការងារ និងចេញសេចក្តីសម្រេចខាងលើហើយអាចប្រើប្រាស់នូវវិធានការចាំបាច់ទាំងអស់ ។

មាត្រា ៣១ ._

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អាចចាត់ចែងឡើងនូវការត្រួតពិនិត្យអធិការកិច្ច ឬការត្រួតពិនិត្យការងារក្នុងរាជបណ្ឌិតសភាកម្ពុជា ក្នុងករណីដែលយល់ថាជាការចាំបាច់ ស្របតាមលក្ខខណ្ឌ និងបែបបទដែលមានចែងក្នុងច្បាប់ និងបទបញ្ញត្តិជាធរមាន ។

## ផ្នែកទី ២
## អាណាព្យាបាលហិរញ្ញវត្ថុ

មាត្រា ៣២ ._

៣២.១. ក្នុងរយៈពេល១៥ថ្ងៃ បន្ទាប់ពីការប្រជុំក្រុមប្រឹក្សាភិបាល ប្រធានរាជបណ្ឌិតសភាកម្ពុជាត្រូវផ្ញើរបាយការណ៍ស្តីពីការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីមានពេលមួយខែ គិតចាប់ពីថ្ងៃទទួលឯកសារ ដើម្បីផ្តល់យោបល់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានពេលពីរខែ គិតចាប់ពីថ្ងៃទទួលឯកសារដែលបញ្ជូនមកដោយប្រធានរាជបណ្ឌិតសភាកម្ពុជា ដើម្បីផ្តល់ការយល់ព្រមលើឯកសារទាំងនេះ ។

៣២.២. លិខិតយល់ព្រមដែលចុះហត្ថលេខាត្រឹមត្រូវ ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬអ្នកតំណាង ត្រូវផ្ញើជូនប្រធានរាជបណ្ឌិតសភាកម្ពុជាដោយមានចំលងជូនរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។ ប្រធានរាជបណ្ឌិតសភាកម្ពុជាត្រូវជម្រាបជំពើងនេះ ជូនក្រុមប្រឹក្សាភិបាលយ៉ាងយាប់បំផុត ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមិនបានឆ្លើយតាមរយៈពេលកំណត់ របាយការណ៍លើការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវចាត់ទុកថាបានទទួលការឯកភាព ។

ប្រសិនបើរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានធ្វើការជំទាស់លើរបាយការណ៍ស្តីពីការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ ប្រធានក្រុមប្រឹក្សាភិបាលត្រូវរៀបចំធ្វើការប្រជុំក្រុមប្រឹក្សាភិបាល ឲ្យបានឆាប់បំផុត ដើម្បីពិភាក្សា និងរិះរកមធ្យោបាយសំរាប់ដោះស្រាយការជំទាស់ទាំងនោះ ។ របាយការណ៍ស្តីពីការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ មិនត្រូវសំរេចយល់ព្រមបានឡើយ ក្នុងករណីមានការជំទាស់ដែលលើកឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពុំទាន់ត្រូវបានដោះស្រាយរួចនៅឡើយនោះ ។

មាត្រា ៣៣ ._

សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល ប្រធានរាជបណ្ឌិតសភាកម្ពុជា ត្រូវដាក់សុំការអនុញ្ញាតជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមការផ្តល់យោបល់ពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ រួមមាន ៖

-សេចក្តីសំរេចស្តីពីការលក់ ឬផ្ទេរសិទ្ធិអចលនទ្រព្យ

-សេចក្តីសំរេចស្តីពីការលើកលែងឥណទេយ្យ ដែលមានទឹកប្រាក់លើសពីការកំណត់របស់ប្រកាសរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-សេចក្តីសំរេចស្តីពីកិច្ចព្រមព្រៀងខ្ចីប្រាក់ និងកិច្ចព្រមព្រៀងសំរាប់ការធានា ឬលិខិតស្រដៀងគ្នានេះ ។

មាត្រា ៣៤ ._

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុធ្វើការតែងតាំងប្រចាំរាជបណ្ឌិតសភាកម្ពុជានូវមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុមួយរូប ដែលត្រូវមានភារកិច្ចធ្វើការត្រួតពិនិត្យជាមុន និងជាក្រោយលើរាជបណ្ឌិតសភាកម្ពុជា ដូចមានចែងក្នុងអនុក្រឹត្យលេខ ៩១ ចុះថ្ងៃទី១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនូវការត្រួតពិនិត្យហិរញ្ញវត្ថុ លើចំណាយថវិកាតាមក្រសួង អង្គភាពមូលដ្ឋានតាមបណ្តាខេត្ត- ក្រុង និងតាមអង្គភាពសាធារណៈដែលមានលក្ខណៈរដ្ឋបាល ។

មាត្រា ៣៥ ._

៣៥.១. ការគ្រប់គ្រងរបស់អាណាប័កដើមខ្សែលើរាជបណ្ឌិតសភាកម្ពុជា ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់អធិការដ្ឋានហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

៣៥.២. ការគ្រប់គ្រងរបស់គណនេយ្យករ ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់គណនេយ្យករកណ្តាលនៃរតនាគារជាតិ និងក្រោមការត្រួតពិនិត្យរបស់អគ្គាធិការដ្ឋានហិរញ្ញវត្ថុ ។

៣៥.៣. រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចាត់ចែងធ្វើការផ្ទៀងផ្ទាត់ អធិការកិច្ច ឬការត្រួតពិនិត្យលើរាជបណ្ឌិតសភាកម្ពុជា នៅពេលដែលយល់ថាចាំបាច់ស្របតាមលក្ខខណ្ឌ និងបែបបទដែលមានចែងក្នុងច្បាប់ និងបទបញ្ញត្តិជាធរមាន ។

## ជំពូកទី ១១

## អវសានប្បញ្ញត្តិ

មាត្រា ៣៦ ._

ការរៀបចំ និងការប្រព្រឹត្តទៅរបស់រាជបណ្ឌិតសភាកម្ពុជា ចាប់ពីថ្នាក់ក្រោមនាយកដ្ឋានចុះ ត្រូវកំណត់ដោយប្រកាសរបស់រាជបណ្ឌិតសភាកម្ពុជា ។

មាត្រា ៣៧ ._

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣៨ ._

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និង ប្រធានរាជបណ្ឌិតសភាកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនឲ្យមានប្រសិទ្ធភាព ។

មាត្រា ៣៩ ._

អនុក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ដើម្បីសូមចុះហត្ថលេខា

ហត្ថលេខា

**សុខ អាន**

ទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី

ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

★★★

## អនុក្រឹត្យលេខ ២៦៧ អនក្រ.តត

## ស្តីពីការតែងតាំងតម្លើងឋានន្តរសក្តិនាយទាហាន

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ.តត ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ ស្តីពីការកែសំរួល រចនាសម្ព័ន្ធចាត់តាំង ក្រសួងការពារជាតិ
- យោងតាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

សំរេច

**មាត្រា ១.-** ត្រូវបានតែងតាំង តម្លើងឋានន្តរស័ក្តិ **ថ្នាក់ឧត្តមសេនីយ៍ឯក** នាយទាហានជាន់ខ្ពស់ នៃ កងយោធពលខេមរភូមិន្ទដូចមានរាយនាមខាងក្រោម ៖

១-វរសេនីយ៍ទោ **ម៉ែន ចាន់តារា** អត្តលេខ ០០១៥៦៥ នាយការិយាល័យ ផលិតកម្ម អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស បច្ចុប្បន្នជា នាយករង នាយកដ្ឋានបំពាក់

២-វរសេនីយ៍ទោ **សូ សុចំន្ទ** អត្តលេខ ០០១៥៦៣ នាយការិយាល័យ ទ័ពអាកាស អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស បច្ចុប្បន្នជា នាយករង នាយកដ្ឋានបច្ចេកទេស

៣-វរសេនីយ៍ទោ **ឌី ទ៉ាន់ឌឹម** អត្តលេខ ០០១៨៣៣ នាយត្រួតពិនិត្យ អគ្គនាយកដ្ឋាន សំភារៈបច្ចេកទេស បច្ចុប្បន្នជា នាយការិយាល័យ សេនានុព័ន្ធ និងជាទីប្រឹក្សាយោធា អមស្ថានទូតប្រចាំនៅ សហព័ន្ធរុស្ស៊ី ។

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃ រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ អគ្គមេបញ្ជាការ នៃ កងយោធពលខេមរភូមិន្ទ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធនិងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

បានជំរាបជូន

សម្តេច នាយករដ្ឋមន្ត្រី

សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

អ្នកឧត្តមស៊ីសុវត្ថិ សិរីវុឌ្ឍ ទៀ បាញ់

***

**អនុក្រឹត្យលេខ ២៦៨ អនក្រ.តត**

**ស្តីពីការតែងតាំង និងកែសំរួលសមាសភាព**

**គណៈកម្មការ POW/ MIA កម្ពុជា**

****

**រាជរដ្ឋាភិបាល**

- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១៩១/អនក្រ.តត ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងប្រធានគណៈកម្មការ **POW / MIA** កម្ពុជា
- យោងតាមសំណើរបស់ប្រធានគណៈកម្មការ **POW / MIA** កម្ពុជា

**សំរេច**

មាត្រា ១ ._ ត្រូវបានតែងតាំង និងកែសំរួលសមាសភាពគណៈកម្មការ **POW / MIA** កម្ពុជា សំរាប់ស្រាវជ្រាវរុករកអដ្ឋិធាតុទាហានអាមេរិកបាត់ខ្លួននៅកម្ពុជា ដូចមានរាយនាមខាងក្រោម ៖

១-ឯកឧត្តមឧត្តមសេនីយ៍ឯក **ម៉ុល សារឿន** អគ្គមេបញ្ជាការរង និងជានាយសេនាធិការចំរុះ នៃកងយោធពលខេមរភូមិន្ទ ជាប្រធាន

២-ឯកឧត្តម **សៀង ឡាប្រេស្ស** អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាអនុប្រធាន

៣-លោក **ជ័យ សាផុន** ប្រធានគណៈកម្មការស្រាវជ្រាវប្រវត្តិសាស្ត្របក្ស ជាអនុប្រធាន

៤-លោក **ជុំ សូយ៉ាត** អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ក្រសួងមហាផ្ទៃ ជាសមាជិកអចិន្ត្រៃយ៍

៥-ឯកឧត្តម អភិបាលខេត្ត ក្រុង ជាសមាជិក

៦ លោក **គឹម ចាន់នី** ប្រធានការិយាល័យ ( អាំងទែរប៉ូល ) ក្រសួងមហាផ្ទៃ ជាសមាជិក

៧-លោក **ខៀវ សាម៉ន** អនុប្រធានមន្ទីរប្រឆាំងគ្រឿងញៀន ក្រសួងមហាផ្ទៃ ជាសមាជិក

៨-លោក **ឆាំ សុខុន** ជំនួយការខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ជាសមាជិក

៩- តំណាងក្រសួងសុខាភិបាល ជាសមាជិក

១០- តំណាងនាយកដ្ឋានអាមេរិក នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាសមាជិក

មាត្រា ២ ._ គណៈកម្មការ **POW / MIA** កម្ពុជា មានភារកិច្ចស្រាវជ្រាវរុករកអដ្ឋិធាតុទាហានអាមេរិក ដោយសហការជាមួយអាជ្ញាធរមូលដ្ឋាន ខេត្ត ក្រុង ដែលមានការពាក់ព័ន្ធ និងត្រៀមទទួលធ្វើការជាមួយគណៈប្រតិភូជំនាញរបស់អាមេរិក អំពីការស្រាវជ្រាវរុករកអដ្ឋិធាតុទាហានអាមេរិកបាត់ខ្លួននៅកម្ពុជា ។

មាត្រា ៣ ._ គណៈកម្មការ **POW / MIA** កម្ពុជា មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិជាផ្លូវការ និងប្រើប្រាស់រថយន្ត ដែលភាគីអាមេរិកបានផ្តល់អោយកន្លងមក ជាមធ្យោបាយធ្វើដំណើរ ។

មាត្រា ៤ ._ សមាជិកគណៈកម្មការ **POW / MIA** កម្ពុជា ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធាន ។

មាត្រា ៥ ._ បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៦ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ ប្រធានគណៈកម្មការ **POW / MIA** កម្ពុជា អភិបាលខេត្ត - ក្រុង រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ២៦៩ អនក្រ.តត

## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងសាធារណការ និងដឹកជញ្ជូន
- យោងតាមតម្រូវការចាំបាច់ការងាររបស់រាជរដ្ឋាភិបាល

## សំរេច

មាត្រា ១ ._ ត្រូវបានតែងតាំងមន្ត្រីរាជការ នៃក្រសួងសាធារណការ និងដឹកជញ្ជូន ដូចមានរាយនាមខាងក្រោម ៖

១-លោក ឈុន ម៉ុនតេខ ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងសាធារណការនិងដឹកជញ្ជូន ។

២-លោក ស៊ីខ ជុនឈួរ ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានដឹកជញ្ជូន និង ជាប្រធាននាយកដ្ឋានដឹកជញ្ជូនផ្លូវគោក នៃក្រសួងសាធារណការ និងដឹកជញ្ជូន ។

មាត្រា ២ ._ បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

***

## ២-សេចក្តីសំរេច

រាជធានីភ្នំពេញ , ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០០

### សេចក្តីសំរេចលេខ ៤៨ សសរ

### ស្តីពីការបង្កើតគណៈកម្មការជំរុញការអនុវត្តន៍កិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលជាមួយក្រុមហ៊ុន អារីស្តុន ស្តីពីការអភិវឌ្ឍន៍តំបន់ក្រុងព្រះសីហនុ និងដោះស្រាយបាតុភាពទំនាស់ដីធ្លី នៅតំបន់អូរត្រេះ

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយក្រុមហ៊ុនអារីស្តុន ចុះថ្ងៃទី ០២ ខែ មករា ឆ្នាំ ១៩៩៥ ស្តីពីការអភិវឌ្ឍន៍តំបន់ក្រុងព្រះសីហនុ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

ប្រការ ១ : បង្កើតគណៈកម្មការសំរាប់ជំរុញការអនុវត្តន៍កិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាល ជាមួយក្រុមហ៊ុន អារីស្តុន ស្តីពីការអភិវឌ្ឍន៍តំបន់ក្រុងព្រះសីហនុ និងដោះស្រាយបាតុភាពទំនាស់ដីធ្លី នៅតំបន់អូរត្រេះ ដែលមានសមាសភាពដូចខាងក្រោម :

១-ឯកឧត្តម ថោង ខុន រដ្ឋលេខាធិការក្រសួងទេសចរណ៍ ជាប្រធាន

២-ឯកឧត្តម ឈុន ស៊ីរុន អភិបាលរងទី១ ក្រុងព្រះសីហនុ ជាអនុប្រធាន

៣-ឯកឧត្តម អ៊ុត ឈន អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអនុប្រធាន

៤-ឯកឧត្តម សយ សុខា អគ្គលេខាធិការក្រុមសង្កេតការណ៍សេដ្ឋកិច្ចសង្គមកិច្ចនិងវប្បធម៌ ជាសមាជិក

៥-លោក លឹម ទ៊ាន់ អគ្គនាយករងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ជាសមាជិក

៦-លោក ចាយ សាមិត ប្រធាននាយកដ្ឋានអភិរក្សធម្មជាតិក្រសួងបរិស្ថាន ជាសមាជិក

៧-លោក ឌី សុតិន តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក

៨-លោក យ៉ា ឡេងហាក់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក

ប្រការ ២ : គណៈកម្មការនេះមានភារកិច្ចដូចតទៅ :

-សិក្សានិងជំរុញការអនុវត្តន៍កិច្ចព្រមព្រៀង

-ដោះស្រាយការលំបាកផ្សេងៗ ក្នុងការអនុវត្តន៍កិច្ចព្រមព្រៀងអោយបានសំរេច

-ស្រាវជ្រាវ និងពិនិត្យដោះស្រាយ បាតុភាពទំនាស់ដីធ្លី នៅតំបន់អូរត្រេះ ក្រុងព្រះសីហនុ

-ខិតខំរករូបមន្តដោះស្រាយបានទាន់ពេលវេលា ក្នុងករណីជួបការលំបាកស្មុគ្រស្មាញ

-រាយការណ៍អំពីដំណើរការអនុវត្តន៍កិច្ចព្រមព្រៀង និងការដោះស្រាយបាតុភាពទំនាស់ដីធ្លីនិងលទ្ធផលជូនរាជរដ្ឋាភិបាល តាមតំណាក់កាល នីមួយៗ

-សមាជិកគណៈកម្មការត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធាន ។

ប្រការ ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន អភិបាលក្រុងព្រះសីហនុ ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

# III- ការងារបណ្ដាក្រសួង

## ១-ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

## ប្រកាស

រាជធានីភ្នំពេញ ,ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០០

**ប្រកាសលេខ ៦៣៥ ឧសករថ.ប្រក**

**ស្ដីពីការបង្កើតគណៈកម្មការ កសាងផែនការមេ របស់ក្រសួង**

***

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្ដីពីការប្រកាសអោយប្រើច្បាប់បង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- យោងស្មារតីអង្គប្រជុំនៅទីស្ដីការគណៈរដ្ឋមន្ត្រី នាថ្ងៃទី០៦/៧/២០០០ ស្ដីពីការត្រៀមលក្ខណៈចូលរួមកសាងផែនការមេ ជាមួយគណៈប្រតិភូ ម៉ាឡេស៊ី
- បានឃើញ ការងារចាំបាច់របស់ក្រសួង

**សំរេច**

**ប្រការ ១ :** បង្កើតគណៈកម្មការកណ្ដាលមួយ ដែលមានសមាសភាពដូចខាងក្រោមនេះ ដើម្បីកសាងផែនការមេ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និង សហការធ្វើការជាមួយប្រតិភូផែនការមេនៃប្រទេស ម៉ាឡេស៊ី :

| | | |
|---|---|---|
| ១-ឯកឧត្តម ស៊ុយ សែម | រដ្ឋមន្ត្រី | ប្រធាន |
| ២-ឯកឧត្តម អ៊ិត ប្រាំង | រដ្ឋលេខាធិការ | អនុប្រធាន |
| ៣-ឯកឧត្តម ញ៉ែប ប៊ុនជិន | រដ្ឋលេខាធិការ | អនុប្រធាន |
| ៤-ឯកឧត្តម ហ៊ុល លឹម | អនុរដ្ឋលេខាធិការ | សមាជិក |
| ៥-ឯកឧត្តម ខួត វ៉ាន់ឌី | អនុរដ្ឋលេខាធិការ | សមាជិក |
| ៦-ឯកឧត្តម គោគ សុវណ្ណរិទ្ធ | អនុរដ្ឋលេខាធិការ | សមាជិក |

៧-ឯកឧត្តម គង់ ចន្ធថា អនុរដ្ឋលេខាធិការ សមាជិក
៨-ឯកឧត្តម ញ៉ឹក ច្រឹង អនុរដ្ឋលេខាធិការ សមាជិក
៩-ឯកឧត្តម ខួន នៅ អគ្គនាយកឧស្សាហកម្ម សមាជិក
១០-ឯកឧត្តម សួទ ជីវគុណ អគ្គនាយកធនធានរ៉ែ សមាជិក
១១-លោក កែវ សុទត្ថិ ប្រធាននាយកដ្ឋានកិច្ចការឧស្សាហកម្ម សមាជិក

ប្រការ ២ : គណៈកម្មការកណ្តាលនេះ មានភារកិច្ចរៀបចំផែនការមេរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដោយសហការជាមួយបេប្រតិភូផែនការមេរបស់ប្រទេសម៉ាឡេស៊ី ដើម្បីជាមូលដ្ឋានសំរាប់កសាងផែនការមេថ្នាក់ជាតិ ។

ប្រការ ៣ : បង្កើតអនុគណៈកម្មការចំនួន ០៥ សំរាប់ជំនួយការអោយគណៈកម្មការកណ្តាល ដែលមានសមាសភាពដូចតទៅ :

ក/-អនុគណៈកម្មការឧស្សាហកម្ម

១-ឯកឧត្តម ហ៊ុល លឹម អនុរដ្ឋលេខាធិការ ប្រធាន
២-ឯកឧត្តម ខួន នៅអគ្គនាយកឧស្សាហកម្ម អនុប្រធាន
៣-លោក កែវ សុទត្ថិ ប្រធាននាយកដ្ឋានកិច្ចការឧស្សាហកម្ម សមាជិក
៤-លោក សាត សមុទ្រ ប្រធាននាយកដ្ឋានបច្ចេកទេសឧស្សាហកម្ម សមាជិក
៥-អ្នកស្រី យុន ទារី ប្រធាននាយកដ្ឋានឧស្សាហកម្មតូច សិប្បកម្ម សមាជិក
៦-លោក ស៊ិន សូណា អនុប្រធាននាយកដ្ឋានកិច្ចការឧស្សាហកម្ម សមាជិក

ខ/-អនុគណៈកម្មការផ្គត់ផ្គង់ទឹកស្អាត និង មាត្រាសាស្ត្រ

១-ឯកឧត្តម គោគ សុវណ្ណរិទ្ធ អនុរដ្ឋលេខាធិការ ប្រធាន
២-ឯកឧត្តម ខួន នៅ អគ្គនាយកឧស្សាហកម្ម អនុប្រធាន
៣-លោក ម៉េង ណារិទ្ធ ប្រធាននាយកដ្ឋានទឹកស្អាត សមាជិក
៤-លោក ហូ ការ៉េម ប្រធាននាយកដ្ឋានមាត្រាសាស្ត្រ សមាជិក

គ/- អនុគណៈកម្មការ ថាមពល

១-ឯកឧត្តម ខួត វ៉ាន់ឌី អនុរដ្ឋលេខាធិការ ប្រធាន
២-លោក ទី នរិន្ទ អគ្គនាយករងអគ្គិសនីកម្ពុជា អនុប្រធាន ,
៣-លោក ឌន់ លាន ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ថាមពល សមាជិក
៤-លោក សាត សាមី ប្រធាននាយកដ្ឋានបច្ចេកទេសថាមពល សមាជិក
៥-លោក ម៉ុន ណារិទ្ធ ប្រធាននាយកដ្ឋានវារីអគ្គិសនី សមាជិក

ឃ/- អនុគណៈកម្មការភូគព្ភសាស្ត្រ រ៉ែ

១-ឯកឧត្តម គង់ ចន្ធថា អនុរដ្ឋលេខាធិការ ប្រធាន

២-ឯកឧត្តម សុខ ជីវគុណ អគ្គនាយកធនធានរ៉ែ អនុប្រធាន

៣-លោក សុខ ឡេង ប្រធាននាយកដ្ឋានធនធានរ៉ែ សមាជិក

៤-លោក ឃុន បញ្ញាសិដ្ឋ ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ធនធានរ៉ែ សមាជិក

៥-លោក សៀង សុថាម ប្រធានការិយាល័យភូគព្ភសាស្ត្រ សមាជិក

ង/- អនុគណៈកម្មការ ផ្ទៃក្នុង

១-ឯកឧត្តម ញ៉ឹក ច្រឹង អនុរដ្ឋលេខាធិការ ប្រធាន

២-លោក ម៉ិន លាង អគ្គនាយករងឧស្សាហកម្ម អនុប្រធាន

៣-លោក គឹម នួច ប្រធាននាយកដ្ឋានបុគ្គលិក សមាជិក

៤-លោក រស់ សារិន ប្រធាននាយកដ្ឋាន រដ្ឋបាល សមាជិក

៥-លោក យក់ ម៉ិនសឺន ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ សមាជិក

ប្រការ ៤ : អនុគណៈកម្មការនេះមានភារកិច្ច រៀបចំផែនការមេ តាមផ្នែករៀងៗខ្លួន សហការផ្ទាល់ជាមួយប្រតិភូម៉ាឡេស៊ី ដោយផ្តល់នូវចក្ខុវិស័យ និង វិស័យផ្សេងៗ សំរាប់ជាមូលដ្ឋានក្នុងការកសាងផែនការមេ របស់ក្រសួង ។

ប្រការ ៥ : អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋាន នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ និង សាមីជនដូចមានចែងក្នុងប្រការ ១ និងប្រការ ៣ មានភារកិច្ចអនុវត្តក្នុងក្របខ័ណ្ឌសមត្ថកិច្ចរៀងៗខ្លួនតាមប្រកាសនេះ ។

ប្រការ ៦ : ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្ត ចាប់ពីកាលបរិច្ឆេទចុះហត្ថលេខាតទៅ ។

ហត្ថលេខា និងត្រា

ស៊ុយ សែម

***

## ២-ឧិស្តីការរដ្ឋមន្ត្រី ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

### ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០០

### ប្រកាសលេខ ១៤០ បទ.ប្រក
### ស្តីពីការ បង្កើតអនុគណៈកម្មាធិការអន្តរក្រសួង
### ពត៌មានវិទ្យា និង មីក្រូអេឡិចត្រូនិក

***

### រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៦៦/អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការបង្កើតគណៈកម្មាធិការ ជាតិទាំង ៦ សំរាប់កិច្ចសហប្រតិបត្តិការ អាស៊ាន ផ្នែកជំនាញ
- បានឃើញកំណត់ហេតុលេខ ៧៤ អស.កបហ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ស្តីពីកិច្ចប្រជុំគណៈកម្មាធិការបច្ចេកទេស វិទ្យាសាស្ត្រ COST របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញសេចក្តីសំរេច នៃកិច្ចប្រជុំថ្នាក់ដឹកនាំក្រសួង ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០០០
- បានឃើញការងារចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ : ត្រូវបានបង្កើតអនុគណៈកម្មាធិការ អន្តរក្រសួង ផ្នែកពត៌មានវិទ្យា និង មីក្រូអេឡិចត្រូនិក ( Sub Committee On Microelectronics and Information Technology " SCMIT " ) ដែលមានសមាសភាព ដូចខាងក្រោមនេះ :

១-ឯកឧត្តម ទូយ គឹមស៊ា អនុរដ្ឋលេខាធិការ ប្រធាន

២-តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សមាជិក

៣-តំណាងក្រសួងពត៌មាន សមាជិក

៤-តំណាងក្រសួងអប់រំ យុវជន និង កីឡា សមាជិក

៥-តំណាងក្រសួងសាធារណការ និង ដឹកជញ្ជូន សមាជិក

៦-តំណាងរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល សមាជិក

ប្រការ ២ : អនុគណៈកម្មាធិការអន្តរក្រសួង ( Sub Committee On Microelectronics and Information Technology " SCMIT " ) មានភារកិច្ចទទួលខុសត្រូវរាល់ការងារដែលទាក់ទង ទៅនឹងបច្ចេកទេស ផ្នែកពត៌មានវិទ្យា និង មីក្រូអេឡិចត្រូនិក ។

ប្រការ ៣ : រាល់ប្រកាសទាំងឡាយណាដែលផ្ទុយពីខ្លឹមសារ នៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៤ : ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជ.រដ្ឋមន្ត្រី
រដ្ឋលេខាធិការ
ហត្ថលេខា និងត្រា
ផាន់ គិន